**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង
## រវាង
## តំណាងរោងចក្រ ខ្វាន់ទុម ខ្លូស៊ីង (ខេមបូឌា) លីមីធីត
## និង
## ប្រតិភូបុគ្គលិក និងកម្មករ និយោជិត

## ស្តីអំពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃពុធ ទី២៧ ខែមករា ឆ្នាំ២០២១ វេលាម៉ោង០៩:៣០ព្រឹក នៅក្នុងរោងចក្រ **ខ្វាន់ទុម ខ្លូស៊ីង (ខេមបូឌា) លីមីធីត** មានកិច្ចប្រជុំមួយ រវាងតំណាងក្រុមហ៊ុន និងប្រតិភូបុគ្គលិក និងកម្មករនិយោជិត នៅក្នុងរោងចក្រអំពីការព្យួរកិច្ចសន្យាការងារ ។

នៅក្នុងអង្គប្រជុំនេះ តំណាងក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រថា ក្រុមហ៊ុនយើងខ្វះការបញ្ជាទិញដោយសារការផ្ទុះនៃវីរុសកូវីត-19 ដែលជាហេតុនាំអោយអតិថិជនមួយចំនួនមិនបានដាក់ការបញ្ជាទិញសំលៀកបំពាក់ពីរោងចក្រ ដែលមិនអាចអោយខ្សែចង្វាក់ផលិតកម្មរបស់រោងចក្រទាំងមូលដំណើរការបាន ហេតុដូចនេះ ក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងារកម្មករ និយោជិតចំនួន.....733.....នាក់ ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន....1054....នាក់ រយៈពេលចំនួន**២៧ថ្ងៃ** គឺចាប់ពី**ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១៣ ខែមិនា ឆ្នាំ២០២១** ហើយនៅក្នុងអំឡុងពេលនៃការព្យួរកិច្ចការងារនេះ កម្មករនិយោជិតបានឯកភាពទទួលយកប្រាក់ឈ្នួលដែលក្រុមហ៊ុនបានផ្តល់ជូនតាមសេចក្តីណែនាំលេខ០៤៥ កប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

អង្គប្រជុំបានចប់វេលាម៉ោង១១ព្រឹក នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងមានភាពស្និតស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួល និងសហការគ្នាយ៉ាងរលូន។

ភ្នំពេញ.ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១

**ប្រតិភូបុគ្គលិក និង កម្មករនិយោជិត** | **នាយកក្រុមហ៊ុន**

QUANTUM CLOTHING (CAMBODIA) LIMITED

Tan Yuanming